រាជរដ្ឋាភិបាលកម្ពុជា

**គជអប**
**NCDD**

**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

# ផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៧ របស់ គ.ជ.អ.ប.

**គ.ជ.អ.ប. មានសមិទ្ធផលរំពឹងទុក០៥ និងលទ្ធផលរំពឹងទុក៣៧ ក្នុងឆ្នាំ២០១៧ ដែលត្រូវសម្រេចឱ្យបាន**

**សមិទ្ធផលរំពឹងទុកទី១: ការគ្រប់គ្រងការងារកំណែទម្រង់៖**

ការលើកកម្ពស់ការគ្រប់គ្រងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យសំដៅការគ្រប់គ្រងដែលជានាំឱ្យមានការផ្លាស់ប្តូរ។ ផែនការចំណាយថវិកាសរុបរបស់សមិទ្ធផលរំពឹងទុកទី១មានចំនួន២.៨៨៥.២៦១ ដុល្លារអាមេរិក។

**លទ្ធផលរំពឹងទុក៖**

1. ការរៀបចំកិច្ចប្រជុំរបស់ គ.ជ.អ.ប. យ៉ាងហោចចំនួន២លើកក្នុងមួយឆ្នាំ






ដើម្បីដឹកនាំ និងសម្របសម្រួលការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

2. ការរៀបចំ និងការអនុម័តផែនការអនុវត្តរយៈពេលបីឆ្នាំ (២០១៨-២០២០) ដំណាក់កាលទី៣នៃកម្មវិធីជាតិ (ផអ៣ទី៣)។
3. ការរៀបចំ និងការអនុវត្តយុទ្ធសាស្ត្រ ដើម្បីលើកកម្ពស់និរន្តរភាពនៃកិច្ចដំណើរការរបស់លេខាធិការដ្ឋាន គ.ជ.អ.ប.។
4. ការពង្រឹង និងការអនុវត្តកិច្ចដំណើរការអភិបាលកិច្ចការកសាងផែនការ និងការត្រួតពិនិត្យនិងវាយតម្លៃនៃ ផអ៣។
5. ការពង្រឹង និងការអនុវត្តនីតិវិធីគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុរបស់ គ.ជ.អ.ប.។
6. ការអនុវត្តយុទ្ធសាស្ត្រពីការប្រាស្រ័យទាក់ទង សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
7. ការពង្រឹងការសម្របសម្រួល និងការប្រឹក្សាយោបល់ជាប្រចាំរវាង លេខាធិការដ្ឋាន គ.ជ.អ.ប. ជាមួយក្រសួង ស្ថាប័ន និងកម្មវិធីកំណែទម្រង់នានា អំពីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
8. ការពិនិត្យឡើងវិញ និងការសម្រួលរចនាសម្ព័ន្ធ និងការទទួលខុសត្រូវរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តមុខងារដែលបានផ្ទេរ។

**សមិទ្ធផលរំពឹងទុកទី២: គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ៖ គណៈអភិបាលត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ។ ផែនការចំណាយរបស់សមិទ្ធផលរំពឹងទុកនេះមានថវិកាសរុបចំនួន៤.៨១៥.២៩៣ដុល្លារអាមេរិក។**

**លទ្ធផលរំពឹងទុក៖**

1. ការពិនិត្យ និងកែសម្រួលប្រព័ន្ធ និងនីតិវិធីនានានៃអភិបាលកិច្ចមូលដ្ឋាន ដើម្បីលើកកម្ពស់ខ្សែគណនេយ្យភាពនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
2. ការអនុវត្តផែនការអនុវត្ត ការងារគណនេយ្យភាពសង្គមក្នុងស្រុកគោលដៅចំនួន៩០។
3. ការរៀបចំ និងការដាក់ឱ្យអនុវត្តយន្តការសម្រុះសម្រួលដោះស្រាយបណ្តឹងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។




4. ការរៀបចំ និងអនុម័តឯកសារគោលនយោបាយ/ ឯកសារទស្សនទាន ស្តីពីអភិបាលកិច្ចរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុកក្នុងការអនុវត្តតាមក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។
5. ការពិនិត្យមើលឡើងវិញ និងការកែសម្រួលប្រព័ន្ធគ្រប់គ្រងរដ្ឋបាល និងប្រព័ន្ធប្រតិបត្តិការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ពិសេសរដ្ឋបាលក្រុង ស្រុក ខណ្ឌ។
6. ការរៀបចំ ការធ្វើសមាហរណកម្ម និងការអនុវត្តនូវប្រព័ន្ធទិន្នន័យសម្រាប់ការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយរដ្ឋបាលក្រុង ស្រុក ខណ្ឌ។



*កិច្ចប្រជុំរវាងប្រជាពលរដ្ឋ និងអង្គភាពផ្តល់សេវា (រដ្ឋបាលឃុំ មណ្ឌលសុខភាព សាលារៀន) ដើម្បីរៀបចំផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម*

**សមិទ្ធផលរំពឹងទុកទី៣: ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស៖ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានប្រព័ន្ធគ្រប់គ្រងមួយ ប្រកបដោយស្វ័យភាព និងប្រសិទ្ធភាព ដើម្បីសម្រេចបាននូវអាណត្តិ និងអាទិភាពផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន។ ផែនការចំណាយរបស់សមិទ្ធផលរំពឹងទុកនេះ មានថវិកាសរុបចំនួន៧.៩៦៨.១០០ដុល្លារអាមេរិក។**

**លទ្ធផលរំពឹងទុក៖**

1. ការរៀបចំ និងការដាក់ឱ្យអនុវត្តនូវសេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។
2. ការលើកកម្ពស់ និងការបញ្ជ្រាបយេនឌ័រ និងបរិយាប័ន្ននិងសមធម៌សង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
3. ការលើកកម្ពស់សមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិដោយប្រើប្រាស់ស្ថាប័នរដ្ឋាភិបាល



ដែលមានស្រាប់ និងកិច្ចសហការរវាងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជននានា។

4. ការលើកកម្ពស់សមត្ថភាពសមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងកិច្ចដំណើរការនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។
5. ការរៀបចំ និងការអនុម័តផែនការអនុវត្តន៍សម្រាប់ការបង្កើត និងការគ្រប់គ្រងសាលាជាតិរដ្ឋបាលមូលដ្ឋាន។

**សមិទ្ធផលរំពឹងទុកទី៤: ការផ្តល់សេវា និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ៖** **រដ្ឋបាលថ្នាក់ក្រោមជាតិអាចឆ្លើយតបចំពោះការរំពឹងទុករបស់ប្រជាពលរដ្ឋក្នុងការទទួលសេវា និងអាចបម្រើសេវាសំខាន់ៗនៅថ្នាក់រដ្ឋបាលដែលនៅកៀកជិតប្រជាពលរដ្ឋ។ ផែនការចំណាយនៃសមិទ្ធផលរំពឹងទុកនេះ មានថវិកាសរុបចំនួន ១៩.៩៦៦.១៤៥ដុល្លារអាមេរិក។**

**លទ្ធផលរំពឹងទុក៖**

1. ការលើកកម្ពស់ការផ្តល់សេវាសង្គម ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និង ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការអនុវត្តមូលនិធិក្រុងស្រុក និងមូលនិធិឃុំ សង្កាត់។
2. ការផ្ទេរ និងការអនុវត្តការប្រគល់មុខងារពាក់ព័ន្ធនឹងគ្រប់គ្រងការអប់រំ



***ឯកឧត្តម ច័ន្ទ សុផល*** *អភិបាលខេត្តបាត់ដំបង ធ្វើការប្តេជ្ញាចិត្តក្នុងការអនុវត្តមុខងារពាក់ព័ន្ធនឹងការគ្រប់គ្រង ការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធឱ្យមានប្រសិទ្ធភាពខ្ពស់ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៦*




*គ.ក.ន.ក. ពិគ្រោះយោបល់ជាមួយម្ដាយរបស់កុមារអំពីផលប្រយោជន៍នៃការចុះសំបុត្រកំណើតឱ្យកូន និងលើកទឹកចិត្តឱ្យបញ្ជូនកូនទៅសាលាមត្តេយ្យ*

កុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធដោយរដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្ត ចំនួន១យ៉ាងតិច។

3. ការរៀបចំនិងការផ្ទេរមុខងារពីក្រសួងចំនួន២ផ្សេងទៀតយ៉ាងតិចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដូចជា ក្រសួងសង្គមកិច្ច ក្រសួងសុខាភិបាល ជាដើម។ល។
4. ការរៀបចំរបាយការណ៍ស្ដីពីការវិភាគមុខងារ និងការពិនិត្យមើលឡើងវិញនូវមុខងារ និងលិខិតបទដ្ឋាននានាស្ដីពីការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ក្រសួង ចំនួន១០ផ្សេងទៀត។
5. រដ្ឋបាលថ្នាក់ក្រោមជាតិគោលដៅអនុវត្តមុខងារដែលបានផ្ទេរប្រកបដោយប្រសិទ្ធភាព ដោយសហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា។
6. ការរៀបចំ និងការផ្ទេរមុខងារនានាស្ដីពីការគ្រប់គ្រងសេវាទីប្រជុំជនពីខេត្តទៅឱ្យរដ្ឋបាលក្រុង ស្រុកគោលដៅ។
7. ការបង្កើត និងកិច្ចដំណើរការនៃការិយាល័យច្រកចេញចូលតែមួយ និងយន្តការ ច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត និងថ្នាក់ក្រុង ស្រុក ខណ្ឌ ចំនួន៥២។

**សមិទ្ធផលរំពឹងទុកទី៥: វិមជ្ឈការហិរញ្ញវត្ថុ៖ ធនធានហិរញ្ញវត្ថុត្រូវបានគ្រោងរៀបចំ ចាត់ចែងនិងមានចំនួនសមស្របសម្រាប់រដ្ឋបាលក្រុង ស្រុក។ ផែនការចំណាយរបស់សមិទ្ធផលរំពឹងទុកនេះ មានថវិកាសរុបចំនួន ៤០៣លានដុល្លារអាមេរិក។**

**លទ្ធផលរំពឹងទុក៖**

1. ការបង្កើនមូលនិធិក្រុង ស្រុកសមាសភាគអភិវឌ្ឍន៍ ដើម្បីបង្កលក្ខណៈឱ្យក្រុង ស្រុកមានធនធានសមស្របសម្រាប់អនុវត្តមុខងារជាអាណត្តិទូទៅរបស់ខ្លួន។
2. ការពិនិត្យមើលឡើងវិញ និងការរៀបចំរបាយការណ៍រួមគ្នាស្ដីពីលក្ខខណ្ឌសម្រាប់ការចំណាយមូលនិធិក្រុង ស្រុកផ្នែកអភិវឌ្ឍន៍។

3. ការដាក់ឱ្យអនុវត្តនូវយន្តការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។
4. ការរៀបចំឯកសារគោលនយោបាយស្តីពីចំណូល និងចំណាយសម្រាប់រយៈ ពេលវែង និងរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
5. ការបន្តការរៀបចំ និងការដាក់ឱ្យអនុវត្តនូវលិខិតបទដ្ឋាននានាស្តីពី ប្រភពចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមបញ្ចូលទាំងការរៀបចំសេចក្តីព្រាងអនុក្រឹត្យស្តីពីចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
6. ការរៀបចំបញ្ចប់ និងការអនុម័តនូវលិខិតបទដ្ឋាន និងសេចក្តីណែនាំនានាស្តីពីការអនុវត្តគម្រោងគាំទ្រ ដោយមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ។
7. ការរៀបចំ និងការអនុវត្តគម្រោងគាំទ្រដោយមូលនិធិវិនិយោគថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព និងតម្លាភាព។
8. ការពិនិត្យមើលឡើងវិញ និងការអនុម័តនូវលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការរៀបចំ និងការប្រព្រឹត្តទៅនៃថវិការាជធានី ខេត្ត។
9. ការលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពនៃការអនុវត្តនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
10. ការផ្សព្វផ្សាយ និងការណែនាំសេចក្តីណែនាំបច្ចេកទេសស្តីពីកិច្ចដំណើរការកសាងផែនការអភិវឌ្ឍន៍ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមប្រភេទថ្នាក់រដ្ឋបាលនីមួយៗ។
11. ការពង្រឹងការផ្សព្វផ្សាយ និងការប្រើប្រាស់ទិន្នន័យមូលដ្ឋាន និងឯកសារពាក់ព័ន្ធ រួមបញ្ចូលទាំងទិន្នន័យអំពីសេវាសង្គម ការប្រែប្រួលអាកាសធាតុសម្រាប់កិច្ចដំណើរការ នៃការកសាងផែនការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។



*អគាររដ្ឋបាល និងសាលប្រជុំថ្មីរបស់រដ្ឋបាលស្រុកកោះញែក ក្រោមកម្ចីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)*

**ដៃគូអភិវឌ្ឍន៍៖** Sida ADB

**លេខាធិការដ្ឋាន គ.ជ.អ.ប៖** ស្ថិតក្នុងបរិវេណក្រសួងមហាផ្ទៃ មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ:+855 (0)23 362 175 អ៊ីមែល: info@ncdd.gov.kh
គេហទំព័រ: www.ncdd.gov.kh ទំព័រ Facebook: www.ncdd.gov.com/mcdds